RÉPUBLIQUE FRANÇAISE
*Liberté*
*Égalité*
*Fraternité*

INSTITUT FRANÇAIS
*Liberté*
*Créativité*
*Diversité*

# លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មផ្នែកការប្រលងរបស់វិទ្យាស្ថានបារាំងនៅកម្ពុជា

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះរួមបញ្ចូលដោយភាគីវិទ្យាស្ថានបារាំងដែលមានទីតាំងនៅភ្នំពេញ( កម្ពុជា ) មានឈ្មោះថា"IFC"និងភាគីម្ខាងទៀតជារូបវ័ន្តឬជានីតិបុគ្គលដែលប្រើប្រាស់សេវាកម្មរបស់វិទ្យាស្ថានបារាំងមានឈ្មោះថា "**អតិថិជន** "។

## គោលបំណង

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មផ្នែកប្រលងនេះមានគោលបំណងកំណត់ទំនាក់ទំនងកិច្ចសន្យារវាង IFC រួមទាំងលក្ខខណ្ឌអនុវត្តទាំងឡាយចំពោះការទិញ/ប្រើប្រាស់សេវាកម្មដោយអតិថិជនជាលក្ខណៈអាជីពក្តីឬមិនមែនអាជីពក្តី។

សេវាកម្មរបស់ IFC ត្រូវបានផ្តល់ជូននៅទូទាំងប្រទេសកម្ពុជាដោយក្រុមការងាររបស់ IFC។

ការទទួលបានទំនិញឬសេវាកម្មពី IFC មានន័យថាអតិថិជនបានយល់ព្រមទាំងស្រុងនូវលក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះ។

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះគ្របដណ្តប់លើលក្ខខណ្ឌទាំងអស់ឬលក្ខខណ្ឌដោយឡែកដែលមិនបានចែងច្បាស់លាស់ដោយ IFC ។

IFC រក្សាសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌទូទៅនៃការលក់សេវាកម្មរបស់ខ្លួននៅពេលណាក៏បាន។ ក្នុងករណីនេះអតិថិជននឹងត្រូវផ្តល់សុពលភាពលើលក្ខខណ្ឌទូទៅនៃការលក់ទាំងនេះម្តងទៀតនៅពេលចុះឈ្មោះលើកក្រោយ។

សេវាកម្មផ្តល់ជូនដូចមានក្នុងគេហទំព័ររបស់ IFC : www.ifcambodge.com

សេវាកម្មផ្តល់ជូនដោយ IFCមានបីផ្នែក : មជ្ឈមណ្ឌលភាសា, បណ្ណាល័យ និងផ្នែកវប្បធម៌។ ចំពោះផ្នែកបណ្ណាល័យនិងផ្នែកវប្បធម៌លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនិងត្រូវអនុវត្តតាមករណីនីមួយៗនិងត្រូវទំនាក់ទំនងតាមពេលវេលាសមស្រប។

សម្រាប់សេវាកម្មទាំងអស់ដែលស្ថិតនៅក្រោមលក្ខខណ្ឌទូទៅនេះ តម្លៃដែលបង្ហាញនៅលើគេហទំព័រ គឺគិតជាដុល្លារអាមេរិក។

RÉPUBLIQUE FRANÇAISE
*Liberté Égalité Fraternité*

INSTITUT FRANÇAIS — *Liberté Créativité Diversité*

# មាត្រា១ - វិញ្ញាបនប័ត្រ

## A. លក្ខខណ្ឌទូទៅ

វិទ្យាស្ថានមានរៀបចំការប្រលងវាស់ស្ទង់កម្រិតភាសាបារាំងដែលធ្វើតាមការសរសេរលើក្រដាសផ្ទាល់តែប៉ុណ្ណោះ ដូចជា DELF Prim, DELF Junior, DELF/DALF Tout Public ។ TCF Tout Public, TCF Canada, TCF Québec TCF IRN, TEF IRN, TEF Canada, TEF Québec និង TEF AU និង ការប្រលងវាស់ស្ទង់កម្រិតភាសាបារាំង DFP ជំនួញទំនាក់ទំនងអន្តរជាតិសុខាភិបាលនិងទេសចរណ៍-សណ្ឋាគារ-ភោជនីយដ្ឋាន ត្រូវប្រលងតាមកុំព្យូទ័រ។

## B. ការចុះឈ្មោះប្រលង

បេក្ខជនអាចចុះឈ្មោះ តាមអនឡាញ (www.ifcambodge.com) ឬចុះឈ្មោះដោយផ្ទាល់នៅមណ្ឌលប្រលង។ រាល់ការចុះឈ្មោះគឺសម្រាប់តែបុគ្គលម្នាក់ៗមិនអាចផ្ទេរឲ្យបុគ្គលផ្សេងបានទេហើយអាចធ្វើទៅបានក្នុងអំលុងពេលចុះឈ្មោះតែប៉ុណ្ណោះ។ ការសុំប្តូរកម្រិត សុំដកប្រាក់ ឬសុំព្យួរការប្រលង នឹងមិនអាចធ្វើទៅបាននោះទេ ក្រោយការចុះឈ្មោះត្រូវបានបញ្ចប់។

## C. ការសុំព្យួរការប្រលង ឬ សុំដកប្រាក់វិញ

ការសុំព្យួរការប្រលងពាក់ព័ន្ធនឹងករណីចាំបាច់ អតិថិជនត្រូវភ្ជាប់ឯកសារមានសុពលភាពមកជាមួយ។ការសុំដកប្រាក់មិនអាចធ្វើទៅបានទេក្រោយការចុះឈ្មោះត្រូវបានបញ្ចប់។ អតិថិជនមិនមានសិទ្ធិសុំព្យួរការប្រលងបានទេក្រោយពេលដែលលិខិតកោះប្រលងបានផ្ញើទៅឲ្យគាត់ហើយនោះ។

## D. ការផុតកាលកំណត់បង់ថ្លៃប្រលង

ការចុះឈ្មោះប្រលងចាត់ចូលជាផ្លូវការបន្ទាប់ពីបេក្ខជនបានឯកភាពលើលក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មប្រលង។ ការទូទាត់ថ្លៃប្រលងត្រូវធ្វើត្រឹមកាលបរិច្ឆេទកំណត់ដោយ IFC ។ ការទូទាត់ជាដុល្លារឬជាលុយរៀលអាចបង់បានតាមរយៈធនាគារដៃគូ តាមកាតធនាគារ តាមការផ្ទេរប្រាក់នៅធនាគារ ឬតាម QRកូដ ដែលដាក់ឱ្យប្រើប្រាស់ ។
បេក្ខជនត្រូវបង់ថ្លៃប្រលងទាំងអស់ក្នុងពេលតែមួយ។

RÉPUBLIQUE FRANÇAISE
*Liberté Égalité Fraternité*

INSTITUT FRANÇAIS *Liberté Créativité Diversité*

### E. លិខិតកោះប្រលង

កាលបរិច្ឆេទប្រលងត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រវិទ្យាស្ថាន https://ifcambodge.com/examens-et-certifications/ និងនៅលើពាក្យចុះឈ្មោះប្រលង។ វិទ្យាស្ថាននឹងផ្ញើលិខិតកោះប្រលងតាមអ៊ីមែលដល់បេក្ខជន។ លិខិតកោះប្រលងនេះបញ្ជាក់ពីថ្ងៃនិងម៉ោងប្រលងផ្លូវការនៃវិញ្ញាសារនីមួយៗ។ បេក្ខជនត្រូវប្រាកដថាមកប្រលងតាមកាលបរិច្ឆេទមាននៅលើលិខិតកោះប្រលងស្រាប់។ ក្នុងករណីយឺតយ៉ាវបេក្ខជនមិនត្រូវបានអនុញ្ញាតឱ្យចូលបន្ទប់ប្រលងឡើយ។ ករណីអវត្តមានពេលប្រលង អតិថិជនមិនអាចដកប្រាក់វិញបានទេ។

### F. ថ្ងៃប្រលង

បេក្ខជនត្រូវបង្ហាញលិខិតសម្គាល់ខ្លួនផ្លូវការ(សំណៅដើម)ដែលមានសុពលភាពនិងលិខិតកោះប្រលងជាក្រដាសនៅពេលមកដល់មណ្ឌលប្រលង។ បេក្ខជនត្រូវប្រើតែប៊ិចព័ណខ្មៅឬខៀវប៉ុណ្ណោះ។ ពេលប្រលងហាមសួរគ្នា ឬសួរអ្នកខាងក្រៅ និងហាមផ្លាស់ប្តូរឯកសារឬសម្ភារៈគ្នា។ រាល់ការប្រព្រឹត្តខុសឆ្គងនឹងត្រូវទទួលពិន័យ។

### G. លទ្ធផលប្រលង និង សញ្ញាប័ត្របណ្តោះអាសន្ន

មណ្ឌលប្រលងនឹងផ្តល់ដំណឹងដល់បេក្ខជនតាម អ៊ីមែលនៅពេលចេញលទ្ធផលប្រលងក្នុងរយៈពេល២សប្តាហ៍ ចំពោះការប្រលង TCF និង DFP បេក្ខជននឹងទទួលដំណឹងតាមអ៊ីមែលដែរ។ បេក្ខជនអាចមកដកសញ្ញាប័ត្របណ្តោះអាសន្នបានឬក៏ដកព្រឹត្តិបត្រពិន្ទុក្នុងករណីប្រលងធ្លាក់នៅកន្លែងចុះឈ្មោះ។ ពេលនោះដែរបេក្ខជនក៏អាចសុំធ្វើការកែប្រែព័ត៌មានផ្ទាល់ខ្លួន ក្នុងអំលុងពេលមួយសប្តាហ៍ បន្ទាប់ពីថ្ងៃចេញលទ្ធផលប្រលងរួច។ ក្រោយកាលបរិច្ឆេទនេះគ្មានការកែប្រែទេ។ បេក្ខជនអាចស្នើសុំមើលសន្លឹកកិច្ចការរបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវឯកសារអត្តសញ្ញាណ ទៅមណ្ឌលប្រលងភ្នំពេញក្នុងកំឡុងពេល១ឆ្នាំ បន្ទាប់ពីចេញលទ្ធផលហើយ។ ការស្នើសុំមើលសន្លឹកកិច្ចការ ត្រូវសរសេរមកមណ្ឌលប្រលង certifications@ifcambodge.com

គណៈវិនិច្ឆ័យមានអធិបតេយ្យភាព។ សេចក្តីសម្រេចរបស់គណៈវិនិច្ឆ័យ គឺដាច់ណាត់ និង រឹងមាំ ។ បេក្ខជនមិនអាចតវ៉ាបានទេ លើកលែងតែករណីកំហុសខាងសំភារៈឬអប្រក្រតីភាពក្នុងលក្ខខណ្ឌនៃការដំណើរការប្រលង។

H. **សញ្ញាប័ត្រ**

សញ្ញាប័ត្រអាចដកបាននៅមណ្ឌលភាសានៃវិទ្យាស្ថានបារាំង យ៉ាងយូរបំផុត៤ខែបន្ទាប់ពីការប្រលងត្រូវបានបញ្ចប់។ សញ្ញាប័ត្រនឹងត្រូវរក្សាទុកកំឡុង៥ឆ្នាំ។

## មាត្រា២ - កម្មសិទ្ធិបញ្ញា

ម៉ាក ឈ្មោះវិស័យ ផលិតផល កម្មវិធីកុំព្យូទ័រ រូបភាព វីដេអូ អត្ថបទ ឬគ្រប់ព័ត៌មាន គ្រប់ឯកសារទាំងអស់សុទ្ធសឹងជាកម្មសិទ្ធិបញ្ញាផ្តាច់មុខរបស់វិទ្យាស្ថានបារាំងតែមួយប៉ុណ្ណោះ។ រាល់ការចំលង ការកែប្រែ ការប្រើប្រាស់ផ្នែកណាក៏ដោយដើម្បីហេតុផលអ្វីក៏ដោយ ត្រូវបានហាមឃាត់ជាដាច់ខាត។

គ្មាននរណាម្នាក់ទទួលបានការអនុញ្ញាតយកឯកសារដូចជាកម្មវិធីកុំព្យូទ័រ ឬរូបភាព ឬឯកសារសំលេងដែលវិទ្យាស្ថានបានដាក់ឱ្យប្រើប្រាស់ទៅបង្កើតថ្មី ធ្វើអាជីវកម្ម ផ្សព្វផ្សាយ ឬផ្សាយបន្ត ទេ ទោះជាមួយផ្នែកណាក៏ដោយ ។

## មាត្រា៣ – ច្បាប់ចតរូបនិងទិន្នន័យផ្ទាល់ខ្លួន

វិទ្យាស្ថានរក្សាសិទ្ធិសុំព័ត៌មានពីអតិថិជន។ តាមរយៈការឯកភាពលើឯកសារនេះ អតិថិជន អនុញ្ញាត្តិឲ្យវិទ្យាស្ថាន៖

- ប្រើប្រាស់ទិន្នន័យអតិថិជនដែលចុះឈ្មោះដើម្បីទទួលបានសេវាកម្ម
- ផ្តល់ទិន្នន័យអតិថិជនដែលចុះឈ្មោះទៅធនាគារដៃគូABA ដោយរក្សាភាពសម្ងាត់ដើម្បីទូទាត់បង់ប្រាក់
- ប្រើប្រាស់រូបភាពអតិថិជនក្នុងក្របខ័ណ្ឌគរុកោសល្យនិងការផ្សព្វផ្សាយរបស់វិទ្យាស្ថាន តែប៉ុណ្ណោះ។

អតិថិជនមានសិទ្ធិចូលមើលនិងកែប្រែទិន្នន័យរបស់ខ្លួន។

## មាត្រា៤ - ករណីជម្លោះ

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មផ្នែកប្រលងស្ថិតក្រោមច្បាប់នៃប្រទេសកម្ពុជា។ ក្នុងករណីមានជម្លោះណាមួយ គូរវិវាទត្រូវដោះស្រាយចំពោះមុខតុលាការក្នុងស្រុក។